# ប្រតិមាសិវយោគិបដ្ដរកឃើញថ្មីនៅតំបន់ស្ទឹងស្ទាប់ ខេត្តកំពង់ធំ

ដូចដែលបានផ្សព្វផ្សាយនៅលើបណ្ដាញសង្គមហ្វេសបុកផ្លូវការ របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ កាលពីរសៀលថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៦ មានការប្រទះឃើញដោយចៃដន្យនូវរូបប្រតិមាធ្វើអំពីថ្មចំនួន ១ (មួយ) ដុំ/អង្គ នៅតំបន់ស្ទឹងស្ទាប់ (ទួលកំពីងក្រវិច) ស្ថិតនៅប៉ែកពាយព្យវត្តពង្រ ចម្ងាយប្រមាណ ៥០០ ម៉ែត្រ ត្រង់ភូមិសាស្ត្រ ភូមិដីមាយ ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។ ប្រតិមានេះរកឃើញដោយលោក **ផាង សុភក្ត្រ** (អ្នកបើកបរគ្រឿងចក្រ) ក្នុងពេលអនុវត្តគម្រោងនៃការស្ដារ និងពង្រីកស្ទឹងស្ទាប់ ដែលអនុវត្តដោយក្រសួងធនធានទឹក និងឧតុនិយម។ ការប្រទះឃើញនេះ ក្នុងពេលដែលគ្រឿងចក្រ (Excavator) ជីកកកាយដីចេញពីស្ទឹង ដើម្បីពង្រីកមាត់ស្ទឹង និងលើកទំនប់ ហើយប្រតិមានេះ រកឃើញនៅក្នុងជម្រៅប្រមាណជិត ២ម៉ែត្រ បើធៀបនឹងមាត់ស្ទឹងស្ទាប់។ តើប្រតិមាធ្វើអំពីថ្មភក់រកឃើញថ្មីនេះ មានអត្តសញ្ញាណ និងលក្ខណៈបែបណាខ្លះ?

ប្រតិមាដែលរកឃើញថ្មីនេះ មានកម្ពស់ ៥៥ ស.ម. ទទឹង ២៤ ស.ម. វិជ្ជមាត្រធំ ២៥ ស.ម. និងទម្ងន់ ៤៨ គ.ក. ហើយធ្វើឡើងអំពីថ្មភក់ដែលអាចមានប្រភពដើមមកពីតំបន់ភ្នំសន្ទុក ដែលស្ថិតនៅមិនឆ្ងាយពីទីតាំងរកឃើញ (ស្ទឹងស្ទាប់) ពោល គឺមានចម្ងាយប្រមាណត្រឹមតែ ៩ គ.ម. ប៉ុណ្ណោះ។ ប្រតិមានេះបាត់ព្រះសិរ អង្គុយក្នុងកាយវិការដោយយកជើងទាំងពីរដាក់ខ្វែងគ្នាជាទម្រង់ "**យោគាសន**" និងចងផ្គោបជើងទាំងសងខាងដោយបន្ទះក្រណាត់ (បដ្ដ) និងកំពុងតែលើកហត្ថទាំងពីរកម្ពស់អញ្ជលីប្រណម្យស្និងស្នាធ៏ធ្វើតបធម៌ ដែលគេស្គាល់ទម្រង់នេះថា "**យោគបដ្ដ**"។ ម្ល៉ោះហើយ គេអាចសន្និដ្ឋានថា ប្រតិមាធ្វើអំពីថ្មភក់ដែលរកឃើញថ្មីនៅតំបន់ស្ទឹងស្ទាប់នេះថា ជារូបតំណាងនៃ "**សិវយោគិបដ្ដ**" ពោល គឺជារូបតំណាងព្រាហ្មណ៍ (អ្នកបួស) ក្នុងនិកាយបាសុបត ឬនិកាយសៃវ នៃលទ្ធិសៃវនិយម ក្នុងព្រហ្មញ្ញសាសនា។

យោងទៅតាមគម្ពីរ បាសុបតសូត្រ (បញ្ចាថ៌ភាស្យ) រៀបរាប់ថា រាល់ការធ្វើយោគ (តបធម៌) របស់ពួកព្រាហ្មណ៍បាសុបត គឺធ្វើឡើងដើម្បីបំផ្លាញកម្មចាស់ មិនបង្កើតកម្មថ្មី និងដើម្បីទទួលបានអំណាចដ៏ទេវភាពរួបរួមជាសាច់តែមួយជាមួយព្រះសិវ។ ដូច្នេះ គោលបំណងចម្បងនៃការធ្វើ "**យោគ**" គឺដើម្បីសម្រេចឱ្យបាននូវ "**ទុក្ខាន្តៈ**" មានន័យថា "**ការរំលត់ទុក្ខជាស្ថាពរ**" ដែលចែកចេញជា ២ គន្លង រួមមាន៖ (១) អសិទ្ធិ គឺការរួចផុតពីចំណងនៃកម្ម និងការចាប់កំណើតថ្មី និង (២)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

*សិទ្ធិ គឺការទទួលបានឋានៈ ឬអំណាចដ៏ទេវភាពដូចព្រះសិវ។ ជាទូទៅ ពួកព្រាហ្មណ៍ ឬអ្នកបួសនៃនិកាយបាសុបតនិងនិកាយសៃវ តែងតែធ្វើយោគ ឬតបធម៌ ឬហៅមួយបែបទៀតថា "ការដុតកំដៅធម៌" មានច្រើនរបៀបណាស់ ដូចជា៖* ***បញ្ចាគ្និតបស*** *(ការតាំងតបៈកណ្ដាលភ្លើង),* ***សិរ៌សន*** *ឬ* ***សិរ៌តបស*** *(ការឈរដាំក្បាលចុះក្រោម),* ***វ្ឫក្សាវលម្ពនតបស*** *ឬ* ***ឧទ៌្វបាទតបស*** *(ការព្យួរខ្លួនបញ្ច្រាសលើដើមឈើ),* ***វាយុស្តម្ភន*** *ឬ* ***វ្យាឃ្រាសន*** *(ការធ្វើសមាធិអណ្ដែតខ្លួន ឬអង្គុយលើស្បែកសត្វ),* ***ឯកបាទតបស*** *(ការឈរជើងមួយ),* ***ជលតបស*** *(ការតាំងសមាធិក្នុងទឹក),* ***ភស្មស្នាន*** *ឬ* ***ភស្មធារណ*** *ឬ* ***ទិគម្ពរតបស*** *(ការដើរអាក្រាតកាយ និងលាបផេះ),* ***យោគបដ្ដសន*** *(ការសមាធិដោយចងក្រណាត់រុំជើង)។*

*ហេតុដូច្នេះហើយ រូបប្រតិមាដែលរកឃើញថ្មីនៅតំបន់ស្ទឹងស្វាប់ដែលបានរៀបរាប់ខាងលើ គឺស្ថិតនៅក្នុងទម្រង់ "**យោគបដ្ដសន**" ដែលមានន័យថា ការធ្វើតបធម៌ដោយមានក្រណាត់ ឬខ្សែរសម្រាប់ចងជាក់ទប់ជង្គង់ទៅនឹងខ្នង ឬចង្កេះ។ ការធ្វើបែបនេះ មានអត្ថប្រយោជន៍ចំនួន ២ យ៉ាង ពោល គឺទី១ ផ្នែករាងកាយ៖ គឺជួយសម្រាលកម្លាំងជង់ខ្លួន មិនឱ្យយោគិធុញទ្រាន់ ឬពោយខ្នង អាចងាយស្រួលអង្គុយធ្វើសមាធិបានរាប់ម៉ោង ឬរាប់ថ្ងៃដោយមិនបាច់ប្រឹងសាច់ដុំ និងទី២ ផ្នែកផ្លូវចិត្ត៖ គឺជានិម្មិតរូបនៃការចងភ្ជាប់ ឬការគ្រប់គ្រងឥន្ទ្រិយទាំងឡាយមិនឱ្យរត់ខ្វាត់ខ្វាយទៅរកលោកិយ។ ក្នុងន័យជារួម ការធ្វើយោគក្នុងទម្រង់ជា "យោគិបដ្ដសន" គឺដើម្បីឈានទៅរកការសម្រេចធម៌ដ៏ប្រសើរខ្ពង់ខ្ពស់ តាមរយៈការកាត់ផ្ដាច់ខ្លួនឱ្យចេញពីលោកិយ និងរំដោះទុក្ខ។*

*បន្ថែមពីនេះ ដើម្បីកំណត់អាយុកាលប្រតិមារកឃើញថ្មីខាងលើនេះ គេត្រូវពិនិត្យទៅលើសិល្បៈជារួម ប៉ុន្តែផ្នែកព្រះសិរដែលងាយស្រួលក្នុងការកំណត់អាយុកាលសិល្បៈ គឺបានបាត់បង់ទៅហើយ។ ចំណែក សម្លៀកបំពាក់វិញ ក៏មិនមានដែរ ពោល គឺនៅសល់តែបន្ទះក្រណាត់ដែលរុំព័ទ្ធចង្កេះតែប៉ុណ្ណោះ។ ម៉្លោះហើយ យើងអាចពិនិត្យទៅលើចំណុច ២ យ៉ាងសំខាន់ៗ គឺទី១ការវិភាគទៅលើទិដ្ឋភាពប្រវត្តិសាស្ត្រនៃការគោរពប្រណិប័តន៍និកាយបាសុបត និងនិកាយសៃវ និងទី២ គឺការវិភាគទៅលើបរិស្ថានជុំវិញ។ ចំពោះចំណុចទី១ ដូចដែលអ្នកស្រាវជ្រាវដឹងមកជាទូទៅថា កាលពីសម័យបុរាណ ខ្មែរបានប្រតិបត្តិនិកាយបាសុបត និងនិកាយសៃវ តាំងពីស.វ.ទី៧ មកម្ល៉េះ ពោល គឺគេអាចមើលឃើញតាមរយៈចម្លាក់ (ព្រះលកុលីស) និងសិលាចារឹកជាច្រើនផ្ទាំង (ឧទាហរណ៍ សិលាចារឹកសំបូរព្រៃគុក K.604 និងសិលាចារឹកភ្នំព្រះវិហារ ខេត្តកំពង់ឆ្នាំង K.733)។ មកដល់រជ្ជកាលព្រះបាទស្រីយសោវរ្ម័នទី១ នាចុងស.វ.ទី៩ ដល់ដើមស.វ.ទី១០ ក្នុងជួររាជការ និងសង្គមខ្មែរទាំងមូលនៅតែបន្តគោរពប្រតិបត្តនិកាយទាំងពីរនេះដដែល ដូចដែលមានបញ្ជាក់*

*អត្ថបទដោយ៖ ម៉ង់ វ៉ាលី*

នៅក្នុងសិលាចារឹកប្រាសាទព្រៃប្រាសាទ K.279។ ម្យ៉ាងហើយ មានន័យថា ទាំងនៅសម័យមុនអង្គរ និងសម័យអង្គរ សង្គមខ្មែរទាំងមូលគឺគោរពប្រតិបត្តិនិកាយទាំងពីរនេះដូចគ្នា។ ដោយឡែកចំណុចទី២ ប្រសិនបើយើងក្រឡេកទៅមើលភូមិសាស្ត្រ និងបុរាណដ្ឋានជុំវិញទីតាំងរកឃើញប្រតិមា (ទួលកំពីងក្រវិច-ស្ទឹងស្វាប់) យើងឃើញថានៅតំបន់នោះសម្បូណ៌ទីតាំងប្រាសាទបុរាណ និងទួលបុរាណច្រើនគួរសម។ វត្ថុសិល្បៈបុរាណដែលប្រទះឃើញនៅតាមទីតាំងបុរាណដ្ឋានទាំងនោះ ភាគច្រើនមានអាយុកាលនៅចុងរចនាបថបាខែង ដល់ដើមរចនាបថកោះកេរ ពោល គឺនៅរវាងដើមស.វ.ទី១០។ ឧទាហរណ៍ ផ្តែរទ្វាររកឃើញនៅប្រាសាទវត្តពជ្រ (ចម្ងាយត្រឹមតែ ៥០០ម៉ែត្រ) និងប្រតិមាព្រះពោធិសត្វអវលោកិតេស្វររកឃើញនៅតំបន់កំពង់លាន-ស្ទឹងស្វាប់ (ចម្ងាយត្រឹមតែ ៣៥០ម៉ែត្រ) សុទ្ធសឹងមានអាយុកាលនៅរវាងចុងស.វ.ទី៩ ដល់ដើមស.វ.ទី១០។ ម្យ៉ាងហើយ ប្រសិនបើយកការវិភាគចំណុចទី១ និងចំណុចទី២ បូកបញ្ចូលគ្នា យើងនឹងឃើញថាប្រតិមាសិវយោគិបដ្ដ ដែលរកឃើញនៅទួលកំពីងក្រវិចនេះ អាចមានអាយុកាលនៅចុងស.វ.ទី៩ ឬដើមស.វ.ទី១០ ក្នុងរវាងចុងរចនាបថបាខែង ដល់ដើមរចនាបថកោះកេរ ហើយករណីនេះមានភាពស៊ីសង្វាក់គ្នាជាមួយរជ្ជកាលព្រះបាទស្រីយសោវរ្ម័នទី១ (គ.ស.៨៨៩ - ៩១០) ដែលទ្រង់ពិតជាបានគោរពប្រណិប័តន៍ចំពោះនិកាយបាសុបត និងសៃវ នៃលទ្ធិសៃវនិយម (ព្រហ្មញ្ញសាសនា) យ៉ាងរឹងមាំ និងជ្រាលជ្រៅបំផុត។

សរុបជារួមមក ប្រតិមាធ្វើអំពីថ្មភក់ដែលបានរកឃើញថ្មីនៅតំបន់ទួលកំពីងក្រវិច (ស្ទឹងស្វាប់) ក្នុងភូមិសាស្ត្រស្រុកសន្ទុក ខេត្តកំពង់ធំ ទំនងជារូបតំណាងនៃ "សិវយោគិបដ្ដ" ពោល គឺជាព្រាហ្មណ៍ ឬអ្នកបួស នៃនិកាយបាសុបត ឬនិកាយសៃវ នៃលទ្ធិសៃវនិយម ក្នុងព្រហ្មញ្ញសាសនា ក្នុងកាយវិការកំពុងតែលើកហត្ថកម្បង់អញ្ជលីប្រណម្យស្មិងស្មាធិ៍ធ្វើតបធម៌ (យោគ) ដោយចងបន្ទះក្រណាត់រុំជើងទាំងពីរ ដើម្បីឈានទៅរកការសម្រេចធម៌ដ៏ប្រសើរខ្ពង់ខ្ពស់ តាមរយៈការកាត់ផ្តាច់ខ្លួនឱ្យចេញពីលោកិយ និងស្វែងរកការរំដោះទុក្ខ។ យោងទៅតាមទិដ្ឋភាពប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងបុរាណដ្ឋានជុំវិញទីតាំងរកឃើញ យើងអាចសន្និដ្ឋានថា ប្រតិមារកឃើញថ្មីនេះទំនងមានអាយុកាលនាសម័យអង្គរ រវាងចុងស.វ.ទី៩ ដល់ដើមស.វ.ទី១០ (ចុងរចនាបថបាខែងដល់ដើមរចនាបថកោះកេរ)។ ការប្រទះឃើញប្រតិមានេះ គឺជាសក្ខីភាពដ៏រឹងមាំមួយបញ្ជាក់ឱ្យដឹងថា នៅតំបន់ស្ទឹងស្វាប់ (ស្រុកសន្ទុក ខេត្តកំពង់ធំ) ជាទីតាំងដែលមានមនុស្សរស់នៅ និងប្រណិប័តន៍ព្រហ្មញ្ញសាសនា និកាយបាសុបត និងនិកាយសៃវយ៉ាងរឹងមាំនៅសម័យបុរាណ។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

## បញ្ជីឯកសារពិគ្រោះ


ម៉ង់ វ៉ាលី, ២០២៥, "ព្រះលកុលីស (ភស្តុតាងផ្នែកប្រវត្តិសិល្បៈនៃនិកាយបាសុបតក្នុងសង្គមខ្មែរ)", អត្ថបទចុះផ្សាយអនឡាញនៅក្នុងគេហទំព័រ *AMS Khmer Civilization* ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០២៥, តាមរយៈតំណភ្ជាប់ https://khmercivilization.ams.com.kh/detail/32383

ម៉ង់ វ៉ាលី, ២០២៥, "បដិមារកឃើញថ្មីនៅតំបន់កំពង់លាន ខេត្តកំពង់ធំ", អត្ថបទចុះផ្សាយអនឡាញនៅក្នុងគេហទំព័រ *AMS Khmer Civilization* ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៥, តាមរយៈតំណភ្ជាប់ https://khmercivilization.ams.com.kh/detail/32835

Acharya, D. 2005. ‘The Role of Caṇḍa in the Early History of the Pāśupata Cult and the Image on the Mathurā Pillar dated Gupta Year 61’, *Indo-Iranian Journal* 48/3–4: 207–222.

Bakker, H.T. 2019. ‘Origin and Spread of the Pāśupata Movement about Heracles, Lakulīśa and Symbols of Masuclinity’, in *Where Art and Text Meet, Studies in the Cultural History of India*, available online in https://www.jstor.org/stable/10.1163/j.ctv2gjwvf9.32

Bhattacharya, K. 1955. ‘La secte des Pāçupata dans l’ancient Cambodge’ *Journal Asiatique*, 243/4: 480-487.

Chemburkur, S. and Kapoor, S. 2018. ‘Pāśupata Sect in Ancient Cambodia and Champa: Art Historical Evidence’, in Vô Vân Thâng and Peter D. Sarrock (eds.), *Masterpiece of the Da Nang Museum of Cham Sculpture*, pp. 45-57, Bangkok: River Books.

Chemburkur, S. 2022. ‘Dancers, Musicians, Ascetics, and Priests: Performance-Based Saiva Worship and its Development in the Temple Cults of Angkor’, in Andrea Acri and Peter Sharrock (eds.), *The Creative South, Buddhist and Hindu Art in Mediaeval Maritime Asia*, pp.192-221, Volume 1.

Choubey, M.C. 1997. *Lakulīsa in Indian Art and Culture,* Delhi: Sharada Publishing House.

Coedès, G. 1937-1966. *Inscription du Cambodge*, Tome I-VIII: Hanoi.

Finot, L. 1928. ‘Nouvelle Inscriptions de Sambor’, *Bulletin de l’École française d’Extrême-Orient,* 28/1: 43-46.

Valy, M. 2023. *Seeing the Diffusion of the Pāśupata Sect into Cambodia in the Seventh Century Based on the Art-Historical Evidence*, Master Dissertation in History of Art and Archaeology, SOAS University of London.





រូបលេខ១-២៖ ប្រតិមាសិវយោគិបដ្ឋរកឃើញនៅតំបន់ស្ទឹងស្វាប់ ស្រុកសន្ទុក ខេត្តកំពង់ធំ
(មើលពីមុខ និងក្រោយ) (ប្រភពរូប៖ សារមន្ទីរខេត្តកំពង់ធំ)





រូបលេខ៣-៤៖ ប្រតិមាសិវយោគិបដ្ឋរកឃើញនៅតំបន់ស្ទឹងស្វាប់ ស្រុកសន្ទុក ខេត្តកំពង់ធំ
(មើលពីចំហៀងខាងស្តាំ និងឆ្វេង) (ប្រភពរូប៖ សារមន្ទីរខេត្តកំពង់ធំ)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៥៖ មន្រ្តីបេតិកភណ្ឌខេត្តកំពង់ធំ និងភាគីពាក់ព័ន្ធ
ចុះពិនិត្យប្រតិមាសិវយោគិបដ្ឋ នៅអធិការដ្ឋាននគរបាលស្រុកសន្ទុក



រូបលេខ២៦៖ ទិដ្ឋភាពប្រគល់-ទទួលប្រតិមាប្រតិមាសិវយោគិបដ្ឋ នៅអធិការដ្ឋាននគរបាល
ស្រុកសន្ទុក ដើម្បីយកមករក្សាទុក និងដាក់តាំងបង្ហាញនៅសារមន្ទីរខេត្តកំពង់ធំ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី